

# ជំនួយដែលមកពីលើ

ប្រមូលគោលគម្ពីរដោយលោក
វ៉ែតសុន - ហ្គូដម៉ែន

ចែកជូន ដោយឥតគិតថ្លៃ

ជំនួយដែលមកពីលើ ព្រះបន្ទូលព្រះមក "ពីលើ" អាចជួយបំពេញចិត្តដែលស្រេកឃ្លាននូវសេចក្តីសុចរិត ។ បើអ្នកណាបានលន់តួនិងលះបង់ចោលបាបរបស់ខ្លួន ហើយទទួលព្រះអង្គសង្គ្រោះគឺព្រះយេស៊ូវគ្រីស្ទឲ្យអស់អំពីចិត្ត ព្រះទ្រង់នឹងបង្ហាញ អង្គទ្រង់ហើយប្រទាននូវសេចក្តីអំណរ និងសេចក្តីសុខមកក្នុងចិត្តរបស់អ្នកនោះ ។ តាំងពីខ្ញុំបានទទួលការសង្គ្រោះពីទ្រង់នៅឆ្នាំ ១៩៣៧ មក ខ្ញុំមិនដែលបានឃ្លាតឆ្ងាយពីសេចក្តីប្រកបដ៏អស្ចារ្យនេះ ពីព្រះអង្គទេ ។ បើអ្នកមិនទាន់ថ្វាយខ្លួនអ្នកដល់ព្រះយេស៊ូវនៅឡើយ សូមអញ្ជើញសម្រេចចិត្តឥឡូវនេះចុះ ។ វ៉ែតសុន - ហ្គូដម៉ែន



## សេចក្តីស្រឡាញ់នៃព្រះ

### យេរេមា ៣១ : ៣

ព្រះយេហូវ៉ាទ្រង់បានលេចមកឲ្យខ្ញុំឃើញកាលពីដើម ដោយបន្ទូលថា អើអញបានស្រឡាញ់ឯង ដោយសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប ហេតុនេះបានជាអញទាញនាំឯងមក ដោយសេចក្តីសប្បុរស ។

### យ៉ូហាន ៣ : ១៦

ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជ



បុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។

### រ៉ូម ៥ : ៨

ព្រះទ្រង់សម្តែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យបានឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសបាបយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង ។

## ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ

### ម៉ាថាយ ១៧ : ៥

កាលគាត់កំពុងតែទូលនៅឡើយ នោះមានពពកយ៉ាងភ្លឺបានមកបាំងគេ ហើយមានឮសម្លេងចេញពីពពកនោះថា នេះជាកូន



ស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់ ចូរស្តាប់តាមចុះ ។

### ១ យ៉ូហាន ៤ : ១៥

អ្នកណាដែលយល់ព្រមថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ អ្នកនោះឈ្មោះថា មានព្រះគង់នៅក្នុងខ្លួនដោយពិត ហើយខ្លួនក៏នៅក្នុងព្រះដែរ ។

### លូកា ១ : ៣៥

ទេវតាក៏ឆ្លើយថា ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូចនេះបុត្របរិសុទ្ធដែលនឹងប្រសូត្រមកនោះ

4 ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ ។

## ព្រះយេស៊ូវជាអ្នកបង្កើត និងជាព្រះអម្ចាស់

### ហេព្រើរ ១ : ២

នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានតម្រូវឲ្យបានគ្រងរបស់ទាំងអស់ ទុកជាមរតក ព្រមទាំងបង្កើតលោកីយ៍ ដោយសារព្រះរាជបុត្រានោះដែរ ។

### រ៉ូម ១៤ : ៩

ដោយហេតុនោះឯង បានជាព្រះគ្រីស្ទទ្រង់សុគត ហើយមានព្រះ

ជន្មរស់ឡើងវិញ គឺដើម្បីនឹងធ្វើជាម្ចាស់ លើទាំងមនុស្សស្លាប់ និង 5
មនុស្សរស់ផង ។

### យ៉ូហាន ១ : ៣

គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ ។

### កិច្ចការ ២ : ៣៦

ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាងឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង ។

6 ## ព្រះយេស៊ូវមានបន្ទូលប្រាប់យើងថាទ្រង់ជានរណា

### យ៉ូហាន ១១ : ២៥

ព្រះយេស៊ូវមានបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ ។

### យ៉ូហាន ៨ : ២៣

ទ្រង់មានបន្ទូលថា អ្នករាល់គ្នាមកពីស្ថានក្រោម ឯខ្ញុំ ៗ មកពីស្ថានលើវិញ អ្នករាល់គ្នាកើតមកពីលោកីយ៍នេះ តែខ្ញុំមិនកើតពីលោកីយ៍នេះទេ ។

### យ៉ូហាន ៩ : ៥ 7

កាលខ្ញុំកំពុងតែនៅក្នុងលោកីយ៍នៅឡើយ នោះខ្ញុំជាពន្លឺនៃលោកីយ៍ ។

### យ៉ូហាន ៦ : ៣៥

ព្រះយេស៊ូវមានបន្ទូលថា ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំក៏មិនត្រូវស្រេកដែរ ។

## អព្ភូតហេតុខ្លះដែលព្រះយេស៊ូវបានធ្វើ

### ម៉ាថាយ ១៤ : ១៩ - ២១

រួចកាលទ្រង់បានបង្គាប់ ឲ្យហ្វូងមនុស្សអង្គុយនៅលើស្មៅ

8 ហើយនោះទ្រង់យកនំបុ័ង ៥ ដុំ និងត្រី ២ នោះងើបទតទៅលើមេឃ ទាំងប្រទានពរ រួចកាច់ប្រទានដល់ពួកសិស្ស ហើយពួកសិស្សក៏ចែកដល់ហ្វូងមនុស្ស ។ គេបានបរិភោគឆ្អែតគ្រប់គ្នា រួចប្រមូលនំចំណិតដែលនៅសល់ដាក់ពេញបាន ១២ កន្ត្រក ។ រីឯពួកមនុស្សដែលបានបរិភោគ នោះមានចំនួន ៥ ពាន់នាក់ ឥតរាប់ពួកស្រី ៗ និងកូនក្មេងទេ ។

### ម៉ាថាយ ២០ : ៣០ និង ៣៤

មានមនុស្សខ្វាក់ ២ នាក់ អង្គុយនៅក្បែរផ្លូវ គេឮថាព្រះយេស៊ូវទ្រង់យាងតាមទីនោះ ក៏ស្រែកឡើងថា ឱ ! ព្រះអម្ចាស់ជាព្រះវង្ស

ហ្លួងដាវីឌអើយ សូមទ្រង់ប្រោសមេត្តាដល់យើងខ្ញុំផង ។ 9

ទ្រង់មានសេចក្តីក្តួលក្នុងព្រះហឫទ័យ ក៏ពាល់ភ្នែកគេ ស្រាប់តែភ្នែកបានភ្លឺឡើង រួចគេដើរតាមទ្រង់ទៅ ។

## ព្រះយេស៊ូវគ្រីស្ទជំនុំជំរះមនុស្សទាំងអស់

### យ៉ូហាន ៥ : ២២

ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់គ្រប់ការជំនុំជំរះដល់ព្រះរាជបុត្រាវិញ ។

### រ៉ូម ១៤ : 10

ហេតុអ្វីបានជាអ្នកនិន្ទាចំពោះបងប្អូនខ្លួន ឬមើលងាយដល់

បងប្អូនខ្លួន ពីព្រោះយើងទាំងអស់គ្នានឹងត្រូវឈរនៅមុខទីជំនុំជំរះរបស់ផងព្រះគ្រីស្ទ ។

**រ៉ូម ២ : ១៦**

គឺក្នុងថ្ងៃដែលទ្រង់នឹងជំនុំជំរះ អស់ទាំងការលាក់កំបាំងរបស់មនុស្ស តាមដំណឹងល្អខ្ញុំ ដោយសារព្រះយេស៊ូវគ្រីស្ទ ។

**២ ធីម៉ូថេ ៤ : ១**

ខ្ញុំផ្តាំមកអ្នករាល់គ្នាយ៉ាងអស់ពីចិត្ត នៅចំពោះព្រះនិងព្រះគ្រីស្ទយេស៊ូវដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង ដោយអាងដំណើរទ្រង់យាងមក និងនគរទ្រង់ ។


## ការប្រោសលោះ ដោយសារតែព្រះគ្រីស្ទ

**យ៉ូហាន ១០ : ៩**

ព្រះយេស៊ូវទ្រង់មានបន្ទូលថា “ខ្ញុំជាទ្វារ បើអ្នកណាចូលតាមខ្ញុំ នោះនឹងបានសង្គ្រោះ រួចនិងចេញចូល ហើយនឹងរកបានវាលស្មៅដ៏ស្រួល ។

**យ៉ូហាន ១៤ : ៦**

ព្រះយេស៊ូវមានបន្ទូលថា ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ ។

**យ៉ូហាន ៨ : ២៤**

អ្នករាល់គ្នានឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួន ពីព្រោះបើមិនជឿថា


ខ្ញុំនេះជាព្រះ នោះអ្នករាល់គ្នានឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួនពិត មែន ។

## ព្រះលោហិតព្រះគ្រីស្ទជាសំណងបាប

**អេភេសូរ ១ : ៧**

ហើយយើងបានសេចក្តីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសឲ្យរួចពីទោស-តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ។

**១ យ៉ូហាន ១ : ៧**

បើយើងរាល់គ្នាដើរក្នុងពន្លឺ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិត


នៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់ ។

## បានសង្គ្រោះដោយសារជំនឿក្នុងព្រះគ្រីស្ទ

**អេភេសូរ ២ : ៨, ៩**

គឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះ ក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ។ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន ។

**រ៉ូម ៥ : ១**

ដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿនោះ


ឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ ។

**យ៉ូហាន ៦ : ២៨, ២៩**

គេទូលសួរទ្រង់ថា ដែលនឹងធ្វើការរបស់ព្រះ តើត្រូវធ្វើដូចម្តេចខ្លះ ។ ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ឯការរបស់ព្រះ គឺឲ្យអ្នករាល់គ្នាបានជឿដល់អ្នកដែលព្រះបានចាត់ឲ្យមក ។

**យ៉ូហាន ២០ : ៣១**

បានចែងទុកតែប៉ុណ្ណេះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រនៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ដោយមានសេចក្តីជំនឿ ។


## សេចក្តីសប្បុរសរបស់ព្រះ

**ទំនុកដំកើង ១០៣ : ១៧**

សេចក្តីសប្បុរសនៃព្រះយេហូវ៉ាស្ថិតស្ថេរនៅតាំងពីអស់កល្បជរាបដល់អស់កល្បជានិច្ច ចំពោះអស់អ្នកដែលកោតខ្លាចដល់ទ្រង់ ។ សេចក្តីសុចរិតរបស់ទ្រង់ ក៏នៅរហូតដល់កូនចៅគេតទៅ ។

**បរិទេវ ៣ : ២២, ២៣**

គឺនឹកពីសេចក្តីនេះថា កុំតែមានសេចក្តីសប្បុរស របស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ ។ សេចក្តីទាំង

នោះចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់ ។

## ព្រះបង្គាប់ឲ្យយើងចូលមក

**ម៉ាថាយ ១១ : ២៨**

ព្រះយេស៊ូវមានបន្ទូលថា អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ។

**យ៉ូហាន ៧ : ៣៧**

ព្រះយេស៊ូវទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ ។



## មិនមែនគ្រប់គ្នាជាកូនរបស់ព្រះទេ

**ភីលីព ២ : ១៥**

ប្រយោជន៍ឲ្យអ្នករាល់គ្នាបានឥតសៅហ្មង ឥតកិច្ចកល ជាកូនព្រះដែលរកបន្ទោសមិនបាន នៅក្នុងតំណមនុស្សវៀច ហើយវិលវូច ដែលអ្នករាល់គ្នាភ្លឺនៅកណ្ដាលគេ ដូចជាតួពន្លឺនៅក្នុងលោក ។

**យ៉ូហាន ១ : ១២**

អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ ។



**១ យ៉ូហាន ៣ : ១០**

គឺយ៉ាងនោះហើយ ដែលនឹងសំគាល់ថាជាពួកកូនព្រះ ឬពួកកូនអារក្សទៅបាន ឯអ្នកណាដែលមិនប្រព្រឹត្តសេចក្ដីសុចរិត ហើយមិនស្រឡាញ់ដល់បងប្អូន នោះមិនមែនមកពីព្រះទេ ។

ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ ។ **រ៉ូម ៨ : ១៤**

## កុំចាញ់បញ្ឆោត

**១ កូរិនថូស ៦ : ៩, ១០**

តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុក


ជាមតិកទេ ឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកអ្នកសម្រេចកិច្ចដោយខ្លួនឯង ពួកលេងកូនដឹង ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល និងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ ។

**១ យ៉ូហាន ៣ : ៧, ៨**

កូនតូចៗរាល់គ្នាអើយ ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើយ អ្នកណាដែលប្រព្រឹត្តសេចក្ដីសុចរិត នោះឈ្មោះថាសុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ ។ តែអ្នកណាដែលប្រព្រឹត្តអំពើបាប


វិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក ដោយហេតុនោះ បានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ ។

## អំពើបាបនាំឲ្យមានសេចក្ដីស្លាប់ រ៉ូម ៥ : ១២

ដូច្នេះដែលបាបបានមកក្នុងលោកីយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ ។



**អេសេគាល ១៨ : ២០**

ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់ កូនមិនត្រូវរងសេចក្ដីទុច្ចរិតរបស់ឪពុកទេ ហើយឪពុកក៏មិនត្រូវរងសេចក្ដីទុច្ចរិតរបស់កូនដែរ សេចក្ដីសុចរិតរបស់មនុស្សសុចរិតនឹងនៅលើអ្នកនោះឯង ហើយសេចក្ដីទុច្ចរិតរបស់មនុស្សទុច្ចរិតនឹងនៅលើខ្លួនអ្នកទុច្ចរិតនោះឯងដែរ ។

**យ៉ាកុប ១ : ១៥**

រួចកាលណាសេចក្ដីប៉ងប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាល

22 ចេញមកជាអំពើបាប ហើយកាលណាបាបបានពោរពេញឡើង
នោះក៏បង្កើតជាសេចក្ដីស្លាប់ ។

## ព្រះគ្រីស្ទបានឈ្នះសេចក្ដីស្លាប់

### វិវរណៈ ១ : ១៨

ព្រះយេស៊ូវមានបន្ទូលថា អញជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើលអញរស់នៅអស់កល្បជានិច្ច រៀងរាបតទៅវិញ អញក៏មានកូនសោរ នៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ ។

### លូកា ៧ : ១៤, ១៥

រួចទ្រង់យាងចូលទៅពាល់ក្ដារមឈូស ឯពួកអ្នកសែងក៏ឈប់ ហើយទ្រង់មានបន្ទូលថា អ្នកកម្លោះអើយ ខ្ញុំបង្គាប់អ្នកថា ចូរក្រោក

ឡើង ។ អ្នកដែលស្លាប់នោះ ក៏ក្រោកឡើងអង្គុយហើយចាប់តាំង 23
និយាយ រួចទ្រង់ប្រគល់ដល់ម្ដាយវិញ ។

## បញ្ញត្តិរបស់ព្រះ

### ចោទិយកថា ៥ : ៧-២១

កុំឲ្យមានព្រះឯណាទៀតនៅមុខអញឲ្យសោះ ។

កុំឲ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឲ្យសោះ ។ ក៏កុំឲ្យក្រាបសំពះនៅមុខរបស់ទាំងនោះ ឬ គោរពប្រតិបត្តិតាមឡើយ ។ កុំឲ្យចេញព្រះនាមព្រះយេហូវ៉ា ជាព្រះនៃឯង ជាអសារឥតការឡើយ ។ ចូរកាន់ថ្ងៃឈប់សំរាក ដើម្បីនឹងថែរក្សាឲ្យបានបរិសុទ្ធ ដូចជាព្រះយេហូវ៉ា ជាព្រះ

24 នៃឯង ទ្រង់បានបង្គាប់មកហើយក្នុងរវាង ៦ ថ្ងៃ នោះត្រូវឲ្យធ្វើអស់
ទាំងការរបស់ឯងចុះ តែដល់ថ្ងៃទី ៧ ជាថ្ងៃឈប់សំរាកនៃព្រះយេហូវ៉ា ជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើការអ្វីឲ្យសោះ ។ ចូរឲ្យគោរពប្រតិបត្តដល់ឪពុកម្ដាយឯង ដូចជាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបង្គាប់មក ដើម្បីឲ្យឯងបានអាយុវែង ហើយឲ្យបានសប្បាយនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងបានប្រទានមក ។

– កុំឲ្យសំឡាប់មនុស្សឲ្យសោះ ។ – កុំឲ្យផិតគ្នាឲ្យសោះ ។
– កុំឲ្យលួចប្លន់ឲ្យសោះ ។ – កុំឲ្យធ្វើជាទីបន្ទាល់ក្លែងទាស់និងអ្នកជិតខាងឯងឡើយ ។ – កុំឲ្យលោភ ។

## អ្នកមិនអាចលាក់អ្វីចំពោះព្រះទេ 25

### យ៉ូប ៣៤ : ២១, ២២

រីឯព្រះនេត្រទ្រង់ បានទតមើលគ្រប់ទាំងផ្លូវរបស់មនុស្ស ក៏ឃើញអស់ទាំងដំណើរដែលគេដើរដែរ ។ គ្មានទីងងឹត ឬ ម្លប់យ៉ាងក្រាសឯណា ដែលពួកអ្នកប្រព្រឹត្តការទុច្ចរិត និងពួនខ្លួនបានទេ ។

### សុភាសិត ១៥ : ៣

ព្រះនេត្រនៃព្រះយេហូវ៉ា នៅគ្រប់អន្លើ ក៏យាមមើលឃើញទាំងអស់ ទោះទាំងអាក្រក់និងល្អផង ។

26

### យេរេមា ២៣ : ២៤

ព្រះយេហូវ៉ា ទ្រង់សួរដូច្នេះទៀតថា តើមានអ្នកណានឹងពួនខ្លួននៅទីសម្ងាត់ឯណា ឲ្យអញមើលមិនឃើញបាន ឬ តើអញមិននៅពេញស្ថានសួគ៌ និងផែនដីផងទេ ឬ អី នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## ការសោយទុក្ខជានិច្ចតទៅ នៃមនុស្សមិនស្គាល់ព្រះ

### ២ ពេត្រុស ៣ : ៧

តែផ្ទៃមេឃនិងផែនដីនៅជាន់នេះ បានបំរុងទុកដល់ថ្ងៃជំនុំជំរះ

ដោយសារព្រះបន្ទូលនៃទ្រង់ សំរាប់ឲ្យភ្លើងឆេះវិញ ហើយបំផ្លាញ 27
មនុស្សទមិលល្មើសចេញ ។

### ទំនុកដំកើង ៩ : ១៧

ពួកមនុស្សអាក្រក់ នឹងត្រូវបំបែរទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ គឺគ្រប់ទាំងសាសន៍ដែលភ្លេចព្រះបង់ ។

### ម៉ាថាយ ១៣ : ៤១, ៤២

គឺកូនមនុស្សនឹងចាត់ពួកទេវតា ទៅប្រមូលយកអស់ទាំងក្បួនដែលនាំឲ្យមនុស្សរវាតចិត្ត និងពួកអ្នកដែលប្រព្រឹត្តទទឹងច្បាប់ ពី

28 នគរបេញ ។ ហើយនឹងបោះគេចោលទៅក្នុងគុកភ្លើង នៅទី
នោះគេនឹងយំ ហើយសង្កៀតធ្មេញ ។

**ត្រូវជំនុំជំរះក្នុងអនាគត**

**២ កូរិនថូស ៥ : ១០**

យើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ ដើម្បី
ឲ្យគ្រប់គ្នា បានទទួលតាមការដែលបានធ្វើ ពីកាលនៅក្នុងរូប
កាយរៀងខ្លួន ទោះល្អឬអាក្រក់ក្តី ។

**២ ពេត្រុស ២ : ៩**

បើដូច្នេះឃើញថា ព្រះអម្ចាស់ទ្រង់ចេះប្រោស មនុស្សដែល

គោរពប្រតិបត្តិដល់ទ្រង់ ឲ្យរួចពីសេចក្តីល្បួង ហើយនិងឃុំទុក 29
មនុស្សទុច្ចរិត សំរាប់និងធ្វើទោស ក្នុងថ្ងៃជំនុំជំរះវិញ ។

**រ៉ូម ១៤ : ១២**

ដូច្នេះយើងទាំងអស់គ្នា នឹងត្រូវរាប់រៀបទូលថ្វាយព្រះពីដំណើរ
របស់ខ្លួនយើងជាមិនខាន ។

**ការប្រែចិត្ត**

ពីដើមព្រះទ្រង់បានទតរំលងគ្រាខ្លៅល្ងង់មែន តែឥឡូវនេះ
ទ្រង់ត្រាស់បង្គាប់ដល់មនុស្សទាំងអស់ នៅគ្រប់អន្លើ ឲ្យប្រែចិត្ត
វិញ ។ **កិច្ចការ ១៧ : ៣០**

30 **កិច្ចការ ៣ : ១៩**

ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នា
បានលប់ចេញ ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះ
អម្ចាស់ ។ **លូកា ១៣ : ៣**

បើអ្នករាល់គ្នាមិនប្រែចិត្តទេ នោះនឹងត្រូវវិនាសទាំងអស់គ្នា ។

**ព្រះអត់ទោសបាប**

**អេសាយ ៥៥ : ៧**

ត្រូវឲ្យមនុស្សអាក្រក់បោះបង់ចោលផ្លូវរបស់ខ្លួន ហើយឲ្យ
មនុស្សទុច្ចរិតចោលគំនិតអាក្រក់របស់ខ្លួនដែរ រួចឲ្យគេត្រឡប់មក

ឯព្រះយេហូវ៉ាវិញ នោះទ្រង់នឹងអាណិតមេត្តាដល់គេ គឺឲ្យវិលមក 31
ឯព្រះនៃយើងរាល់គ្នា ដ្បិតទ្រង់នឹងអត់ទោសឲ្យជាបរិបូណ៌ ។

**អេសេគាល ១៨ : ២១**

តែឯមនុស្សទុច្ចរិត បើបែរចេញពីអស់ទាំងអំពើបាប ដែល
ខ្លួនបានប្រព្រឹត្ត ហើយរក្សាអស់ទាំងក្រិត្យក្រមរបស់អញ ព្រមទាំង
ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើយទៀងត្រង់វិញ អ្នកនោះនឹង
រស់នៅជាពិតឥតត្រូវស្លាប់ឡើយ ។

**ម៉ាថាយ ៦ ១៤**

បើអ្នករាល់គ្នាអត់ទោសចំពោះការរំលងច្បាប់ ដែលមនុស្ស

32 លោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌
ទ្រង់នឹងអត់ទោសឲ្យអ្នករាល់គ្នាដែរ ។

**កំណើតថ្មី**

**អេសេគាល ៣៦ : ២៦**

អញនឹងឲ្យឯងមានចិត្តថ្មី ហើយនិងដាក់វិញ្ញាណថ្មី នៅក្នុង
ឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់ឯងចេញ រួចនឹង
ឲ្យមានចិត្តជាសាច់វិញ ។

**យ៉ូហាន ៣ : ៣**

ព្រះយេស៊ូវមានបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នា

ជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញ 33
នគរព្រះបានទេ ។

**២ កូរិនថូស ៥ : ១៧**

បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជា
ថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំង
អស់បានត្រឡប់ជាថ្មីវិញ ។

**ជីវិតដ៏នៅអស់កល្បជានិច្ច**

**រ៉ូម ៦ : ២៣**

ឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាន

នៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ។

## យ៉ូហាន ៣ : ៣៦

ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្ដីក្រោធរបស់ព្រះតែងនៅជាប់លើអ្នកនោះឯង ។

## យ៉ូហាន ៥ : ២៤

ព្រះយេស៊ូវមានបន្ទូលថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជា


ប្រាកដថា អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្ដីស្លាប់ ទៅដល់ជីវិតវិញ ។

## ភាពប្រាកដនៃសេចក្ដីសង្គ្រោះ

## ១ យ៉ូហាន ៤ : ១៣

គឺយ៉ាងនោះឯង ដែលយើងដឹងថា យើងនៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បានប្រទាន ព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា ។



## អេសាយ ៣២ : ១៧

ឯការនៃសេចក្ដីសុចរិត នោះនឹងបានជាសន្តិសុខ ហើយផលនៃសេចក្ដីសុចរិត នោះនឹងបានជាសេចក្ដីស្រាកស្រាន្ត និងជាសេចក្ដីទុកចិត្តជាដរាបទៅ ។

## យ៉ូហាន ១៤ : ២១

ព្រះយេស៊ូវមានបន្ទូលថា អ្នកណាដែលមានបញ្ញត្តរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង ។

## អំណរមកពីព្រះគ្រីស្ទសណ្ឋិតក្នុងចិត្តយើង



## រ៉ូម ១៤ : ១៧

នគរព្រះមិនសំរេចនឹងការស៊ី ឬ ផឹកនោះទេ គឺស្រេចនឹងសេចក្ដីសុចរិត សេចក្ដីមេត្រី និងសេចក្ដីអំណរ ដោយនូវព្រះវិញ្ញាណបរិសុទ្ធវិញទេតើ ។

## អេសាយ ១២ : ៣

ដោយហេតុនោះ ឯងរាល់គ្នានឹងដងទឹក ពីអណ្ដូងនៃសេចក្ដីសង្គ្រោះដោយអំណរ ។

## ទំនុកដំកើង ១៦ : ១១

ទ្រង់នឹងបង្ហាញឲ្យទូលបង្គំឃើញផ្លូវជីវិតវិញ នៅចំពោះទ្រង់


មានសេចក្ដីអំណរដ៏ពោរពេញ នៅព្រះហស្តស្តាំទ្រង់ មានសេចក្ដីអរសប្បាយ ជាដរាបតទៅ ។

## ការស្ដាប់តាមព្រះ ជាកិច្ចចាំបាច់

## ១ សាំយូអែល ១២ : ១៥

ប៉ុន្តែបើអ្នករាល់គ្នាមិនព្រមស្ដាប់តាមព្រះយេហូវ៉ាទេ គឺទាស់ទទឹងនឹងសេចក្ដីបញ្ញត្តរបស់ទ្រង់វិញ នោះព្រះហស្តនៃព្រះយេហូវ៉ា នឹងបានទាស់នឹងអ្នករាល់គ្នា ។

## ចោទិយកថា ១១ : ២៦ - ២៨

មើលនៅថ្ងៃនេះ អញដាក់ព្រះពរ ហើយនឹងសេចក្ដីបណ្ដាសាសំរែងនៅមុខឯងរាល់គ្នា ។ បើឯងស្ដាប់អស់ទាំងបញ្ញត្តរបស់ព្រះ


យេហូវ៉ាជាព្រះនៃឯង ដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះនឹងបានពរ ។ តែបើមិនស្ដាប់តាមអស់ទាំងបញ្ញត្តរបស់ព្រះយេហូវ៉ាជាព្រះនៃឯងទេ គឺបែរចេញពីផ្លូវដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះទៅតាមព្រះដទៃ ដែលពីដើមមិនបានស្គាល់វិញ នោះឯងនឹងត្រូវបណ្ដាសាហើយ ។

## រ៉ូម ៦ : ១៦

តើអ្នករាល់គ្នាមិនដឹងទេឬអីថា អ្នករាល់គ្នាប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្ដាប់តាមចៅហ្វាយណា នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះឯងដែលអ្នកស្ដាប់តាម ។

## សាតាំងជាសត្រូវយ៉ាងប៉ិនប្រសប់

គ្រានោះព្រះវិញ្ញាណក៏នាំព្រះយេស៊ូវ ទៅឯទីរហោស្ថាន ដើម្បីឲ្យត្រូវអារក្សល្បួង • នោះព្រះយេស៊ូវមានបន្ទូលតបថា នែសាតាំង ចូរឯងថយចេញពីអញទៅ ដ្បិតមានសេចក្ដីចែងទុកមកថា “ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់ តែមួយព្រះអង្គប៉ុណ្ណោះ” ដូច្នេះអារក្សក៏ថយចេញពីទ្រង់ទៅ រួចមានពួកទេវតាមកបំរើទ្រង់ ។ **ម៉ាថាយ ៤ : ១, ១០, ១១**

**១ ពេត្រុស ៥ : ៨**

ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំង

សត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ 
ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ។

**អេភេសូរ ៦ : ១១**

ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួនទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស ។

## ជ័យជំនះលើសាតាំង

**យ៉ាកុប ៤ : ៧, ៨**

ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។ ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹង

 ចូលមកជិតអ្នករាល់គ្នាដែរ ឱពួកមានបាបអើយ ចូរលាងដៃឲ្យស្អាតចុះ ឱពួកអ្នកមានចិត្ត ពីរអើយ ចូរសំអាតចិត្តឡើង ។

**ហេព្រើរ ២ : ១៤**

ដែលកូនចៅបានប្រកបដោយសាច់ឈាម ព្រមគ្នានោះទ្រង់ក៏ទទួលចំណែកជាសាច់ឈាមដូច្នោះដែរ ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្ដីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត ។

**១ យ៉ូហាន ៣ : ៨**

តែអ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ

ពីព្រោះអារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក ដោយហេតុ 
នោះ បានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ ។

## ព្រះយេស៊ូវគ្រីស្ទបានរស់ឡើងវិញ

**រ៉ូម ៤ : ២៥**

ដែលទ្រង់ត្រូវគេបញ្ជូនទៅឲ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឲ្យយើងរាល់គ្នា បានរាប់ជាសុចរិត ។



**ម៉ាកុស ១៦ : ៩**

រីឯកាលទ្រង់មានព្រះជន្មរស់ឡើងវិញ គឺនៅព្រឹកព្រលឹមថ្ងៃទី ១ ក្នុងអាទិត្យនោះឯង នោះទ្រង់ក៏លេចមកមុនដំបូង ឲ្យម៉ារាជាអ្នកស្រុកម៉ាក់ដាឡាឃើញ គឺជាស្ត្រីដែលទ្រង់បានបណ្ដេញអារក្ស ៧ឲ្យចេញនោះ ។

## សេចក្ដីសន្យាដ៏អស្ចារ្យចំពោះអ្នកជឿព្រះគ្រីស្ទ

ទំនុកដំកើង ៣៤ : ១៨

ព្រះយេហូវ៉ាទ្រង់គង់ជិតបង្កើយនឹងអស់អ្នកដែលមានចិត្តសង្រេង

ហើយទ្រង់ជួយសង្គ្រោះ ដល់អស់អ្នកដែលមានវិញ្ញាណទន់ទាប ។ 

**អេសាយ ៦៦ : ២**

ឯរបស់ទាំងនេះ គឺដៃអញបានបង្កើតមក ហើយគឺយ៉ាងនោះដែលរបស់ទាំងនេះបានកើតមានឡើង នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ប៉ុន្តែអញនឹងយកចិត្តទុកដាក់ចំពោះមនុស្ស យ៉ាងនេះវិញ គឺចំពោះអ្នកណាដែលក្រលំបាក ហើយមានចិត្តខ្ទេចខ្ទាំ ជាអ្នកដែលញ័រញាក់ ដោយឮពាក្យរបស់អញ ។

**ទំនុកដំកើង ៣៧ : ៣**

ចូរទុកចិត្តនឹងព្រះយេហូវ៉ា ហើយប្រព្រឹត្តការល្អចុះ យ៉ាងនោះ

46 អ្នកនឹងបាននៅក្នុងស្រុក ហើយចំអែតខ្លួនដោយសេចក្ដីពិត ។

## សេចក្ដីសន្យាចំពោះអ្នកដែលត្រូវល្បួង

### ១ កូរិនថូស ១០ : ១៣

គ្មានសេចក្ដីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្ដីល្បួងដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្ដីល្បួងហួសកម្លាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន ។

### ហេព្រើរ ២ : ១៨

47

ដែលបានរងទុក្ខលំបាក ទាំងត្រូវសេចក្ដីល្បួងនោះទ្រង់ក៏អាចនឹងជួយដល់អស់អ្នក ដែលត្រូវសេចក្ដីល្បួងបានដែរ ។

### ទំនុកដំកើង : ៣៤ : ១៩

មនុស្សសុចរិតតែងកើតមានសេចក្ដីលំបាកជាច្រើន តែព្រះយេហូវ៉ា ទ្រង់ជួយឲ្យរួចពីសេចក្ដីទាំងនោះ ។

## ព្រះគ្រីស្ទយាងមកវិញនៅលើកទី ២

### ម៉ាថាយ ២៤ : ៣០

នោះទីសំគាល់របស់កូនមនុស្ស នឹងលេចមកនៅលើមេឃ

48 គ្រប់ទាំងពូជមនុស្សនៅលើផែនដី នឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្សមកនៅលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង ។

### ម៉ាថាយ ២៤ : ២៧

ដំណើរដែលកូនមនុស្សមក នោះនឹងបានដូចផ្លេកបន្ទោរដែលភ្លឺផ្លេក ៗ ពីទិសខាងកើតដល់ទិសខាងលិច ។

### យ៉ាកុប ៥ : ៨

ចូរឲ្យអ្នករាល់គ្នាអត់ធ្មត់ដូច្នោះដែរ ទាំងតាំងចិត្តឲ្យខ្ជាប់ខ្ជួនឡើង ដ្បិតព្រះអម្ចាស់ជិតយាងមកហើយ ។

## ព្រះបន្ទូលនៃព្រះ

សេចក្ដីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ ។ **២ ពេត្រុស ១ : ២១**

ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង ។ **ទំនុកដំកើង ១១៩ : ១០៥**

### លូកា ២១ : ៣៣

ព្រះយេស៊ូវមានបន្ទូលថា ឯផ្ទៃមេឃនិងផែនដី នោះនឹងកន្លងបាត់ទៅ តែឯពាក្យខ្ញុំ មិនដែលកន្លងបាត់ឡើយ ។